**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

---

# កិច្ចព្រមព្រៀង

ភាគីនិយោជក: លោក **KAZUO SAKAMAKI** ជានាយកក្រុមហ៊ុន **រ៉ុន ឆេស្ទ័ន អ៊ីន** ដែលមានអាសយដ្ឋានស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស តាយ សេង បាវិត ផ្លូវជាតិលេខ១ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង ដែលតទៅនេះហៅថា**ភាគី“ ក ”**។

**និង**

ភាគីប្រតិភូបុគ្គលិក: តំណាងកម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុន **រ៉ុន ឆេស្ទ័ន អ៊ីន** ដែលតទៅនេះហៅថា**ភាគី “ ខ ”** ។

**<u>មូលហេតុ:</u>** ស្របពេលដែលពិភពលោកកំពុងមានករណីឆ្លងជំងឺផ្លូវដង្ហើមដ៏កាចសាហាវ ( កូវីត១៩ ) កើនឡើងជាបន្តបន្ទាប់បានធ្វើឲ្យមានមនុស្សជាច្រើនបានឆ្លងឬបានស្លាប់ និងបានប៉ះពាល់ដល់វិស័យពាណិជ្ជកម្ម ។

ដោយសារបញ្ហាទាំងអស់នេះហើយបានធ្វើឲ្យក្រុមហ៊ុន **រ៉ុន ឆេស្ទ័ន អ៊ីន** ត្រូវបានផ្អាកការបញ្ជាទិញ និងខ្វះសម្ភារៈវត្ថុធាតុដើម ដូចនេះហើយក្រុមហ៊ុនយើងខ្ញុំសម្រេចស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៣៨នាក់ (ស្រី ៣០នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ២០៦នាក់ (ស្រី ១៧៦នាក់) រយៈពេល ០២ខែ ។

**<u>រយៈពេល:</u>** រយៈពេលចំនួន ៦១ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០២០ ដល់ថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០២១។

**<u>ប្រាក់ឈ្នួល:</u>** រយៈពេលនៃការព្យួរកិច្ចសន្យាការងារនេះ ក្រុមហ៊ុននិងមានការផ្តល់ប្រាក់ឧបត្ថម្ភដល់ កម្មករនិយោជិតចំនួន ៣០$ ( សាមសិបដុល្លាអាមេរិកគត់ ) ។

**<u>នីតិវិធីនៃការបើកឧបត្ថម្ភ:</u>** រយៈពេលនៃការបើកប្រាក់ឧបត្ថម្ភ គឺបើករៀងរាល់ថ្ងៃទី១០ នៃខែបន្ទាប់ និងមួយខែបើកម្តង។ ប្រសិនបើការបើកប្រាក់ឧបត្ថម្ភនេះប៉ះចំថ្ងៃអាទិត្យ ឬថ្ងៃបុណ្យត្រូវបើកមុនមួយថ្ងៃនៃថ្ងៃអាទិត្យ ឬថ្ងៃបុណ្យនេះ ។ កម្មករ និយោជិតត្រូវមកបើកនៅក្រុមហ៊ុន រ៉ុនឆេស្ទ័នអ៊ីន ។

បាវិត, ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០២០

**នាយកក្រុមហ៊ុន**

KAZUO SAKAMAKI

**ប្រតិភូបុគ្គលិកពេញសិទ្ធិ**

នេត សំអឿន　　ជុំ ផានិត　　ព្រំ សុភ័ក្រ　　ភឹក ស៊ីព័រ